# អ្នកស្ម័គ្រចិត្ត

## ជួយទ្រទ្រង់-ជួយឧបត្ថម្ភ

- ចាំទ្រាំជម្ងឺ, បំរើជនម្នាក់ដែលមានជម្ងឺរ៉ាំរ៉ៃជរាមិនជាសោះនោះ, អាចជាការ ខូចចិត្តនិងរន្ធត់ណាស់ ។ អ្នកស្ម័គ្រចិត្តបំរើប្តេជ្ញា បន្ធូរ,សំរាលអ្នកចាំទ្រាំនោះដោយផ្តល់នូវជំនួយជាក់ស្តែងមែនទែន រួមផ្សំទាំងជំនួយផ្លូវចិត្តផង។
- ដើម្បីដឹងច្បាស់ថាតើអ្នកត្រូវគេជួយបែបណា,សូមទាក់ទងក្រុមបំរើផ្នែក ជម្ងឺរ៉ាំរ៉ៃប្រចាំតំបន់របស់អ្នក។



## តើនឹងទៅជាយ៉ាងណាទៅ បើសិនជាអ្នក និយាយអង់គ្លេស មិនបានត្រឹមត្រូវ នោះ?

ផ្នែកក្រុម បំរើអ្នកមានជម្ងឺជរា រ៉ាំរ៉ៃ មានការចាំអារម្មណ៏ ជានិច្ចចំពោះវប្បធម៌ឬភាសារបស់អ្នក។ ដូច្នេះ សូមកុំរួញរា ទារសុំថីបកប្រែភាសាផ្ទាល់មាត់ម្នាក់នោះ។ អ្នកអាចប្រើថីបក ឬក៏បងប្អូនអ្នកក៏បាន។

## តើត្រូវសុំ ជំនួយអំពីអ្នកណា ឬក៏ សុំយោបល់ អំពីនរណា

- អំពីគ្រូពេទ្យដែលព្យាបាលអ្នក។
- អំពីកិច្ចការបំរើពួកជម្ងឺរ៉ាំរ៉ៃដែលនៅជិតអ្នកជាងគេ។

Palliative Care Australia Inc gratefully acknowledges the financial assistance of the Commonwealth Department of Health and Aged Care. However the views expressed are those of PCA and may not represent those of the Commonwealth.

Design concept courtesy of the Palliative Care Council of South Australia and Palliative Care Victoria

Palliative Care Australia

## ការថែទាំដល់អ្នកជម្ងឺ រ៉ាំរ៉ៃ

# ជួយបន្ធូរ

# ជួយទ្រទ្រង់

# ជួយឧបត្ថម្ភ

ជួយថែទាំទំនុកបំរុង ជនជាទីស្រឡាញ់ របស់យើង ដែលឈឺជរា ឬមានជម្ងឺរ៉ាំរ៉ៃ



## តើអ្វីទៅជា ផ្នែកសំរាល

## ទុក្ខទទួលបំរើជនជរា ឬអ្នកមានជម្ងឺរ៉ាំរ៉ៃ

ផាល្លីយ៉ាទីវ ឃែ(Palliative Care) គឺជាផ្នែកបំរើ១សំរាប់អ្នកជម្ងឺរ៉ាំរ៉ៃ ឈឺជរាជម្ងឺដែលមិនសង្ឃឹមថាជាសោះ។

វត្ថុបំណងរបស់អង្គការផាល្លីយ៉ាទីវ ឃែ, គឺពង្រឹងពង្រីកឲ្យបានរីកម៉ាំល្អឲ្យតម្លៃកាន់តែខ្លាំងឡើងលើជីវិតមនុស្សម្នាក់ៗ។ កិច្ចការទាំងនោះអាចធ្វើទៅបានដោយ, ប្រើប្រព័ន្ធទំនាក់ទំនង និងផ្តល់ជូននូវកិច្ចការបំរើ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជនម្នាក់ៗ ដែលកំពុងទទួលការព្យាបាល នឹងសំរាលទុក្ខដល់អ្នកថែជម្ងឺផងដែរ។

គេបានដឹងហើយថា មានបញ្ហាជាច្រើនរាប់មិនអស់ ដូចយ៉ាង ផ្នែកសម្ភារៈ , ផ្នែកផ្លូវចិត្ត ផ្លូវកាយ , សង្គម និងសាសនា ក៏ត្រូវការជំនួយ ឬការឧបត្ថម្ភជាក់ស្តែងផងដែរ។

## កិច្ចការជួយធំនុកបំរុង

## បំរើនេះគឺជាធធ្វើជាក្រុម–ជាពួក




## ប្រសិនបើខ្ញុំ ឈឺចុកចាប់,

## តើអាចធ្វើឲ្យវា អន់ថយឬទេ?

ស្ទើរតែគ្រប់ករណី , ការឈឺចុកចាប់ អាចបន្ធូរបន្ថយខ្លះបានដោយប្រើៈថ្នាំបំបាត់ការឈឺចាប់(Painkillers)ឬក៏ឱសថផ្សេងៗ ការច្របាច់សរសៃ , អង្គុយសមាធិ, លាបលនដោយថ្នាំទឹក, ចាក់ម្ជុលអត់ថ្នាំ និង ព្យាបាលដោយប្រើ វិទ្យុកម្ម នឹង ថ្នាំ ឬបែបផ្សេងៗ ។

ឱសថ ថ្មីៗ ទៅតាមបច្ចេកទេសថ្មីឥឡូវនេះ គឺការលេបបញ្ចូលថ្នាំជាតិ ម៉ហ្វីនគ្រាប់ ឬក៏ ថ្នាំប៉ះបិទលើស្បែក ។

## តើផ្តល់ជំនួយ ទៅដល់ទីណាខ្លះ ?

ផ្នែកបំរើ ផាល្លីយ៉ាទីវ ឃែ , អាចជួយ ឬផ្តល់ជំនួយទៅដល់ទីណាក៏បាន ឲ្យតែអាចទៅដល់, ឬក៏គ្រប់ទិសទីតំបន់ដែលអ្នកជម្ងឺចង់រស់នៅ ឬនៅបាន។ អាចផ្តល់ជូនទៅតាមកន្លែងដូចជា៖

- ផ្តល់ជូនទៅដល់ក្នុងផ្ទះអ្នកជម្ងឺតែម្តង, ក៏បានដែរ។
- ទៅបំរើ ឬផ្តល់ជំនួយនៅក្នុង ជំរកជនចាស់ជរាពិការ។
- នៅក្នុងមន្ទីរពេទ្យ ។
- នៅតាមផ្ទះថែទាំមនុស្សចាស់,ណើស្សីង ហូម(Nursing Home)។

ក្រុមគ្រួសារ, សាច់ញាតិ នឹងមិត្រភ័ក្រ្ត គឺជាអ្នកទ្រាំជម្ងឺទី១ ឬដំបូងបំផុត។ ជំនួយឯកទេស,អាចផ្តល់ជូនអំពីបុគ្គលិកផ្នែកផាល្លីយ៉ាទីវ ឃែ(Palliative Care) ។



## តើអ្វីទៅជាមន្ទីរជំរកសំរាប់

## មនុស្សជរាឈឺចាស់(Hospice)

គឺជាទីកន្លែងជំរកប្តេជ្ញាព្យាបាលមនុស្សមានជម្ងឺជាប្រចាំមិនជា, ប្រជុំធ្វើការដោយអ្នកជំនាញៗ មានវេជបណ្ឌិតកំពុងហ្វឹកហាត់, គិលានុប្បដ្ឋាយិកា, សង្គមការី, ពេទ្យជំនាញខាងចាប់សរសៃ, អ្នកស្ម័គ្របំរើ ជាច្រើននាក់ផងដែរ រង់ចាំផ្តល់នូវជំនួយដល់អ្នកជម្ងឺ បូករួមទាំងក្រុមគ្រួសារជាមួយផង , ការគាំទ្ររាប់បញ្ចូលផ្នែក ផ្លូវចិត្ត ផ្លូវកាយ នឹង ផ្លូវសាសនា ជាចាំបាច់៕